ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

ក្រសួងបរិស្ថាន

Ministry of Environment

៣

លេខ: ១៣៤ (ខ.ក) ប.ស្ក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១២

# ប្រកាស
## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "អភិវឌ្ឍន៍ព្រៃវែង" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិព្រៃវែង ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ចុះថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "អភិវឌ្ឍន៍ព្រៃវែង" ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០១២
- តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## សម្រេច

**ប្រការ១** : រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "អភិវឌ្ឍន៍ព្រៃវែង" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិព្រៃវែង ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ។

ប្រការ២ : សហគមន៍តំបន់ការពារធម្មជាតិ "អភិវឌ្ឍន៍ព្រៃវែង" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានទំហំផ្ទៃដីចំនួន ១០៤៨ ហិចតា ដូចមានផែនទីជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម ៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| A | 452613 | 1541195 | G | 457186 | 1538297 |
| B | 453132 | 1541948 | H | 456141 | 1537611 |
| C | 453677 | 1542747 | I | 455389 | 1537516 |
| D | 454650 | 1541710 | J | 454448 | 1539266 |
| E | 455588 | 1540706 | K | 453413 | 1539963 |
| F | 456887 | 1539549 | | | |

ប្រការ៣ : ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "អភិវឌ្ឍន៍ព្រៃវែង" នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពី តំបន់ការពារធម្មជាតិ។

ប្រការ៤ : អគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានកម្រងតំបន់ការពារធម្មជាតិ "ស្ទឹងសែន" ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ នាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងសហគមន៍តំបន់ការពារធម្មជាតិ "អភិវឌ្ឍន៍ព្រៃវែង" ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា

<u>ចម្លងជូន:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សាលាខេត្តព្រះវិហារ
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ផែនទីសហគមន៍តំបន់ការពារ ជាតិ "អភិវឌ្ឍន៍ព្រៃខែង" ស្ថិតក្នុងដែនជម្រក

## ភូមិសាស្ត្រភូមិព្រៃខែង ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ




| Id | N | X | Y |
|---|---|---|---|
| 1 | A | 452613 | 1541185 |
| 2 | B | 453132 | 1541948 |
| 3 | C | 453677 | 1542747 |
| 4 | D | 454650 | 1541710 |
| 5 | E | 455593 | 1540706 |
| 6 | F | 456687 | 1539549 |
| 7 | G | 457188 | 1538207 |
| 8 | H | 456141 | 1537611 |
| 9 | I | 455309 | 1537546 |
| 10 | J | 454443 | 1539266 |
| 11 | K | 453413 | 1539563 |